បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE

# ប្រវត្តិសង្ខេប

# នៃ

# ព្រះពុទ្ធទាំង៥ព្រះអង្គ

# ក្នុងភទ្ទកប្បយើងនេះ

២០៥.
៩២

## ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីស្សូ កូសី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ករុណាខ្មែរ** និង **មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh www.elibraryofcambodia.org

២០៥. ៥២

# ប្រវត្តិសង្ខេប

## នៃ

# ព្រះពុទ្ធទាំង៥ព្រះអង្គ

# ក្នុងភទ្ទកប្បយើងនេះ

BUDDHIST INSTITUTE LIBRARY
៧២៣៩/០២

និពន្ធ និង រៀបរៀង

ដោយ

ឈី សុវីរ

ឆ្នាំច ឆស័ក

ព.ស. ២៥៣៨ ម.ស. ១៩១៦

គ.ស. ១៩៩៤ ច.ស. ១៣៥៦

រក្សាសិទ្ធិ

# អារម្ភកថា

ដោយយល់ឃើញថា នៅឆ្នាំ ១៩៧៥- ៧៩ ប្រទេសខ្មែរ មានវិបត្តិ អ្នកចេះដឹងអរិយធម៌ខ្មែរ ក៏ស្លាប់ស្ទើរគ្មានសល់ ។ ឯឯកសារស្ដីពី អរិយធម៌ខ្មែរ ក៏វិនាសស្ទើរគ្មានសល់ដែរ ។

ការយល់ឃើញបែបនេះ ធ្វើអោយខ្ញុំខំស្រាវជ្រាវរកមើល ឯកសារនានា ដែលមាននិយាយពីអរិយធម៌ខ្មែរ ។ លទ្ធផលស្រាវជ្រាវឃើញមានរឿងព្រះពុទ្ធ ៥ ព្រះអង្គ ដែលបានត្រាស់ដឹង នៅក្នុងភទ្ទកប្បនេះ មាននៅក្នុងសាស្ត្រាក្លែកស និងសាស្ត្រាធម្មតា មហាអនន្តគុណ ខ្សែ ៣ ។

ខ្ញុំបានដកស្រង់ជាគោល ៗ ដោយសង្ខេបយកមកបង្ហាញ ក្លួយ ៗ ដែលចង់ចេះចង់ដឹងពីអរិយធម៌ខ្មែរ អោយបានយល់ដឹងផង ។

១៧៣៥/០៦

សូមអរគុណ

**ឈី.សុធីរ**

*អតីតសាស្ត្រាចារ្យមធ្យមសិក្សា*

**ក្រុកសិទ្ធ**

# ប្រវត្តិសង្ខេប



**លី សុធីរ**

**លី សុធីរ** កើតនៅថ្ងៃពុធ ៦កើត ខែបុស្ស ឆ្នាំរោងព.ស.២៦៧២ត្រូវ នឹងថ្ងៃទី ១៦ ខែមករា ឆ្នាំ១៩២៨ នៅភូមិឫស្សីធ្នង់ ឃុំបឹងព្រះស្រុកបាភ្នំ ខេត្តព្រៃវែង ឪពុកព្រះនាម **លី អែម** ម្ដាយព្រះនាម **ទិន ម៉ាន់**។

ពីអាយុ ១ឆ្នាំ រហូតដល់អាយុ ២០ឆ្នាំ នៅជាមួយឪពុកម្ដាយខំរកស៊ីបំរើឪពុកម្ដាយ គ្មានបានរៀនសូត្រអ្វីទាំងអស់។ លុះដល់អាយុ២១ឆ្នាំ ឪពុកម្ដាយបានអនុញ្ញាតអោយបួសរៀននៅវត្តសិរីមង្គល ហៅព្រៃវាយ ដែលជាវត្តគេរដំនែលពីឪពុក ស្ថិតនៅក្នុងឃុំទឹកថ្លា ស្រុកបាភ្នំ ខេត្តព្រៃវែង បួសនៅក្នុងសំនាក់ព្រះតេជព្រះគុណ គង់ យី ជាព្រះឧបជ្ឈាយ៍, ព្រះតេជព្រះគុណ លី អ៊ុម ជាឧបសម្បទាចារ្យ។

លុះដល់អាយុ ២២ឆ្នាំ បានចេញទៅរៀនភាសាបាលី នៅវត្តព្រៃទំពូង, វត្តព្រែកចង្ក្រានលើ, វត្តសារាវ័ន, វត្តឧណ្ណាលោម។ នៅក្នុងគ.ស.១៩៥៦ បានប្រលងជាប់ចូលរៀន នៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត។ លុះដល់គ.ស.១៩៦៦បានប្រលងបញ្ចប់បរិញ្ញាប័ត្រទស្សនវិជ្ជាសាសនា នៅពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ។

ពេលលាចាកសិក្ខាបទ នៅឆ្នាំ ១៩៦៦ បានធ្វើជាសាស្ត្រាចារ្យនៅពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ ១ឆ្នាំ បានធ្វើការនៅសូណាត្រឹម ២ឆ្នាំ។

នៅឆ្នាំ ១៩៦៧ បានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងនាង ឡាយ ប៊ុនណា នៅភូមិព្រែកថ្មី ស្រុកកៀនស្វាយ ខេត្តកណ្ដាល មានកូនស្រី ៤នាក់ និងកូនប្រុស ៣នាក់។ បច្ចុប្បន្នស្លាប់អស់ ២នាក់ នៅរស់កូនស្រី ៣នាក់ និងកូនប្រុស ២នាក់។

នៅឆ្នាំ ១៩៦៩ បានធ្វើជាសាស្ត្រាចារ្យ នៅវិទ្យាល័យសិរីមង្គល (រការកោង)។ នៅឆ្នាំ ១៩៧២ ធ្វើជាសាស្ត្រាចារ្យនៅវិទ្យាល័យខ្មែរអង់គ្លេស (បឹងត្របែក)។ នៅឆ្នាំ ១៩៧៥ ទៅនៅស្រុកកំណើត។ នៅឆ្នាំ ១៩៧៩ ធ្វើគ្រូនៅសាលាបឋមសិក្សាវត្តបឹងព្រះ។ នៅឆ្នាំ ១៩៨០ធ្វើជាអ្នកនិពន្ធសៀវភៅសិក្សានៅក្រសួងអប់រំ។ នៅឆ្នាំ ១៩៩៧ ខែតុលា ចូលនិវត្តន៍។

ភ្នំពេញ, ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ ១៩៩៨

**លី សុទីរ**

អតីតសាស្ត្រាចារ្យមធ្យមសិក្សា

រក្សាសិទ្ធ

# ប្រវត្តិសង្ខេប
# នៃ
# ព្រះពុទ្ធទាំង ៥ ព្រះអង្គ ដែលបានត្រាស់ដឹង
# ក្នុងភទ្ទកប្បយើងនេះ

~~~~*~~~~

នៅក្នុងគំនូររូបព្រះពុទ្ធទាំង ៥ ព្រះអង្គ ដែលបានត្រាស់ដឹងនៅក្នុងភទ្ទកប្បយើងនេះ គេឃើញរូបនៅក្រោមព្រះពុទ្ធទ្រង់ព្រះនាម **កកុសន្ធោ** គេគូររូបមាន់ ព្រះពុទ្ធទ្រង់ព្រះនាម **កោនាគមនោ** គេគូររូបនាគរាជ, ព្រះពុទ្ធទ្រង់ព្រះនាម **កស្សបោ** គេគូររូបអណ្ដើក ព្រះពុទ្ធទ្រង់ព្រះនាម **គោតមោ** គេគូរូបគោ ព្រះពុទ្ធទ្រង់ព្រះនាម **អរិយមេត្តេយ្យោ** គេគូររូបខ្លា (រឺរូបរាជសីហ៍) [១] ។

គេនាំគ្នាចូល់ថា តើព្រះពុទ្ធទាំង ៥ ព្រះអង្គនេះព្រះអង្គជាសត្វមាន់, ជានាគរាជ, ជាអណ្ដើក, ជាគោ, ជាខ្លា ? រឺព្រះពុទ្ធទាំង ៥ ព្រះអង្គនេះ គ្រាន់តែមានឈ្មោះហៅថា មាន់, នាគរាជ, អណ្ដើក, គោ, ខ្លា ? រឺក៏ព្រះពុទ្ធទាំង ៥ ព្រះអង្គនេះ មានប្រវត្តិបែបណាវិញ បានជាអរិយធម៌ខ្មែរ គេគូររូបមាន់, នាគរាជ, អណ្ដើក, គោ

---

១. ក្នុងសាស្ត្រាស្ដេចក្ងោកសថា រាជសីហ៍, សាស្ត្រាមហាអគ្គគុណថា ខ្លា
~~~~

ខ្លា នៅពីក្រោមបែបនេះទេវិញ ?

ប្រវិត្តនៃព្រះពុទ្ធទាំង ៥ព្រះអង្គនេះ មានជំទាលពិតប្រាកដណាស់ នៅក្នុងសាស្ត្រាក្អែកស និងសាស្ត្រាធម្មតាមហាអនន្តគុណ ខ្សែ៣ ត្រង់សន្លឹកក៦ B តទៅ ។ ខ្ញុំសូមដកស្រង់និងសំរួលដោយសង្ខេប ចេញពីឯកសារខាងលើនេះ ទុកជាអរិយធម៌សំរាប់កូនខ្មែរបានដឹងជាបន្តទៅ ។

ពីអតីតកាលដ៏យូរលង់កន្លងផុតទៅ ជាច្រើនមកហើយ មានស្តេចក្អែកសទាំងគូញីឈ្មោល នាំគ្នាកាច់ជាសំបុកពងនៅលើដើមឈើធំមួយ ក្បែរឆ្នេរសមុទ្រ ។

លុះពងបានចំនួន ៥ ក្អែកស ញី.ឈ្មោល ក៏ចាំថែរក្សាពងដោយយកចិត្តទុកដាក់ណាស់ ។ ថ្ងៃមួយ កកាមហាក្អែកមានការអស្ចារ្យព្រួយចិត្តប្លែកណាស់ ពីព្រោះមានខ្យល់ព្យុះបក់បោកខ្លាំងធ្លាក់ទាំងពង ទាំងសំបុកទៅក្នុងទឹក រសាយរសាត់ព័ព្ធអណ្តែតតាមទឹកអស់ទៅ ។

កាលនោះក្អែកសញី.ឈ្មោល ស្រែកយំសោកស្រនោះអាល័យពង ហិចហើរឆ្វេឆ្វាទៅតាមឆាបឆក់យកពងពីក្នុងទឹកមកវិញពុំបាន ។ ក្អែកសញី.ឈ្មោលព្រួយចិត្តខ្លាំងទាល់តែស្លាប់ ។ ក្អែកសញីឈ្មោល បានទៅចាប់កំណើតនៅស្ថានព្រហ្មលោកទាំងពីរមាន

ឈ្មោះហៅថា គគោចមហាព្រហ្ម សោយសម្បត្តិរហូតមកដល់សព្វថ្ងៃនេះ ។

ពងទាំង ៥នេះ ទេះតែអណ្តែតចេញពីគ្នា ឆ្ងាយទៅ ១ ។ តែតួអង្គព្រះពុទ្ធ ពុំដែលវេទនាដូចពងមាន់ពងទាឡើយ ។ ពងក្អែកអណ្តែតច្រាសទឹក មានពន្លឺមហិមាគួរអោយអស្ចារ្យណាស់ ។

ពងទី១ អណ្តែតទៅដល់សត្វមាន់.មាន់រើសយកទៅរក្សាទុក ពងទី ២ អណ្តែតទៅដល់ស្តេចនាគរាជ.ស្តេចនាគរាជរើសយកទៅថែរក្សាទុក ។ ពងទី ៣ អណ្តែតទៅដល់សត្វអណ្តើក.អណ្តើករើសយកទៅថែរក្សាទុក ។ ពងទី ៤ អណ្តែតទៅដល់សត្វគោ. គោរើសយកទៅថែរក្សាទុក ។ ពងទី៥ អណ្តែតទៅដល់សត្វខ្លា.ខ្លារើសយកទៅថែរក្សាទុក ។

សត្វទាំង៥ គឺមាន់.នាគរាជ.អណ្តើក.គោ.ខ្លា. ខំយកពងដែលខ្លួនរើសបាន ទៅទុកថែរក្សាប្រាស់ រហូតដល់គំរប់ថ្ងៃ ខែ ពងទាំង៥ញាស់ព្រមគ្នា ។ សត្វទាំង៥នេះ ពេលធំឡើងកាលណា ក៏ប្រែកាឡាជាមនុស្សទាំងអស់ ។ ដើម្បីធ្វើខ្លួនអោយបានត្រាស់ដឹងជាព្រះពុទ្ធ មនុស្សកាឡាខ្លួនទាំង ៥នាក់ ខំធ្វើចិត្តអោយបានបរិសុទ្ធ ខំរក្សាសីល ខំចំរើនមេត្តាភាវនា អោយសុក្រិតមួយថ្ងៃបន្តិច ១ ជាដរាប។

លុះខំធ្វើចិត្តអោយបានបរិសុទ្ធយូរៗ ទៅ ឃើញថាមិនសូវបានផលល្អ មនុស្សទាំង៥ បានលាអ្នកថែរក្សាព្យាបាលខ្លួនចេញទៅធ្វើធម៌ ។ អ្នកទាំង ៥ បានចេញដំនើរតំនាលគ្នា ទៅជួបគ្នានៅកន្លែងមួយ ។ អ្នកទាំង៥ នាក់ ក៏សន្ទនាសាកសួរគ្នាទៅវិញទៅមក ទើបដឹងថា សុទ្ធតែជាអ្នករក្សាសីលដូចគ្នា ។

អ្នកទាំង ៥ បបួលគ្នាចុះឆ្លងទឹកស្ទឹងទៅត្រើយម្ខាង តែទឹកស្ទឹងនោះជ្រៅពេកមិនអាចឆ្លងទៅបាន ក៏នាំគ្នាឈររង់ចាំមើលក្រែងមានអ្នកណាម្នាក់ គេអុំទូកមក នឹងសុំគេអោយជួយចំលងទៅត្រើយស្ទឹងម្ខាង នឹងបានទៅរក្សាសីល ចំរើនមេត្តាភាវនានៅទីនោះ ។

ពេលនោះស្រាប់តែមានស្រីម្នាក់ឈ្មោះនាង **មយ៉ិមយា** បានរៀបចាយទឹកនំចំនីអាហារជូនមាតាបិតាពិសាររួចហើយ នាងបណ្ដាលចិត្តអោយទៅរកអុស រកបន្លែ រកផ្លែឈើធ្វើជាអាហារជូនមាតាបិតា ហេតុតែសំនាងនាងនឹងបានជាពុទ្ធមាតា ក្នុងភទ្ទកប្បនេះ ។ នាងចាប់ចែវ ច្រវា អុំទូកល្បឿនស្ទេវទៅដល់បុរសទាំង ៥ ដែលនៅឈរចាំតាមផ្លូវនោះ ។

បុរសទាំង៥ កាលបើឃើញនាង **មយ៉ិមយា** អុំទូកមកដល់ស្រែកហៅនាងសុំអោយនាងជួយចំលងខ្លួនទៅត្រើយម្ខាង។ នាង

មយីមយាអុំទូកទៅដល់លិសំរែកហៅ នាងបង្អង់ទូក ។ បុរសទាំង ៥នោះសួរទៅសួរថា អ្នកនឹងអញ្ជើញទៅណាមកណា សុំចំលង យើងផង ។ នាងតបថា អ្នកឆ្លងទៅណា ? បុរសនោះឆ្លើយថា សុំ ឆ្លងទៅត្រើយស្ទឹងម្ខាង ។ នាងសួរទៀតថា អ្នកឆ្លងទៅប្រាថ្នាការ អ្វី ?បុរសឆ្លើយថា នាងអើយខ្ញុំទាំងនេះ នឹងរកកន្លែងរក្សាសីល។ នាងសួរទៀតថា អ្នកទៅរកកន្លែងរក្សាសីល តើប្រាថ្នាជាអ្វី ?

បុរសទាំង៥ ឆ្លើយថា ប្រាថ្នាអោយបានត្រាស់ដឹងជាព្រះ ពុទ្ធ ។បើដូចនោះអ្នកប្រាថ្នាជាព្រះពុទ្ធ ខ្ញុំសុំជាម្តាយអ្នកទាំង៥ ខ្ញុំនឹង សុខចិត្តចំលងអ្នកទាំង ៥ ទៅត្រើយស្ទឹងនាយ ។ ឯបុរសទាំង ៥ នោះត្រេកអរណាស់ ឆ្លើយតបវិញថា សាធុ ៗ សំដីនាងពិរោះពេក ហោង ។

នាង មយីមយាបានចំលងបុរសទាំង៥នោះ ទៅដាក់ត្រើយ ស្ទឹងនាយតាមបំនងបុរសទាំង ៥នោះ ។ ដូចនេះ ទើបនាង មយី មយា ត្រូវបានជាពុទ្ធមាតាព្រះពុទ្ធទាំង ៥ព្រះអង្គ ក្នុងភទ្ទកប្បនេះ ឯង ។

កាលបើព្រះពុទ្ធទាំង ៥ព្រះអង្គនេះ បានត្រាស់ដឹងឡើងក្នុង លោកព្រះអង្គបាននឹកឃើញដល់ពាក្យបណ្តាំរបស់សត្វទាំង ៥ គឺ មាន់.នាគរាជ.អណ្តើក.គោ.ខ្លា ( ក្នុងសាស្ត្រាស្តេចក្អែកសថារាជ

សីហ៍ ) ក្នុងពេលដែលព្រះអង្គមួយអង្គៗ បានលាចេញទៅធ្វើធម៌ សត្វទាំង ៥ បានផ្តាំថាបើកូនបានត្រាស់ជាព្រះពុទ្ធ សូមអោយកូនយកឈ្មោះម្តាយជាអ្នកថែរក្សា ទៅដាក់ជាឈ្មោះរបស់ខ្លួន ក្នុងពេលដែលកូនបានត្រាស់ដឹងជាព្រះពុទ្ធនោះឯង ។

លុះជាតិជាទីបំផុត ព្រះអង្គបានត្រាស់ដឹងឡើងក្នុងលោក ទើបយកឈ្មោះម្តាយជាអ្នកថែរក្សា ទៅដាក់ជាឈ្មោះខ្លួនតាមបណ្តាំ :-

១.បុរសដែលមាន់ចិញ្ចឹមថែរក្សា ដាក់ឈ្មោះថា **កកុសន្ធោ**

២ . បុរសដែលនាគរាជចិញ្ចឹមថែរក្សា ដាក់ឈ្មោះថា **កោនាគមនោ**

៣. បុរសដែលអណ្តើកចិញ្ចឹមថែរក្សា ដាក់ឈ្មោះថា **កស្សបោ**

៤.បុរសដែលគោចិញ្ចឹមថែរក្សា ដាក់ឈ្មោះថា **គោតមោ**

៥. បុរសដែលខ្លា រីរាជសីហ៍ចិញ្ចឹមថែរក្សា ដាក់ឈ្មោះថា **អរិយមេត្តេយ្យោ** ( ព្រះសិអារ្យមេត្រី ) ។

មូលហេតុនេះហើយ ទើបបុព្វបុរសខ្មែរ ផ្នែកខាងវិចិត្រករ (ជាងគំនូរ ) លោកយករូបមាន់ ទៅគូរដាក់នៅក្រោមព្រះពុទ្ធទ្រង់ព្រះនាម **កកុសន្ធោ** , យករូបនាគរាជ ទៅគូរដាក់នៅក្រោមព្រះ

ពុទ្ធទ្រង់ព្រះនាម **កោនាគមនោ** យករូបអណ្តើក ទៅគូរដាក់នៅក្រោមព្រះពុទ្ធទ្រង់ព្រះនាម **កស្សបោ** . យករូបគោទៅគូរដាក់នៅក្រោមព្រះពុទ្ធទ្រង់ព្រះនាម **គោតមោ**. យករូបខ្លាវី រាជសីហ៍ ទៅគូរដាក់នៅក្រោមព្រះពុទ្ធទ្រង់ព្រះនាម **អរិយមេត្តេយ្យោ** ( ព្រះសិអារ្យមេត្រី ) ទុកជាប្រវត្តិតទៅ រហូតមកដល់សព្វថ្ងៃនេះ ។

ធ្វើចប់នៅថ្ងៃទី ១៥ មករា ឆ្នាំ ១៩៩៥

**លី សុធីរ**

**គ្រោសិទ្ធិ**

*អ្នកវាយកុំព្យូទ័រ នាង សុខ ចិន្តា*